# ព្រះរាជក្រឹត្យ

នស/រកត/០២០៩/១៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០១០០/០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានកែសម្រួលមាត្រា ២ របស់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០០ / ០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដូចតទៅ៖

**មាត្រា ២ ថ្មី:** គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រួមមានសមាសភាព៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ឱម យ៉ិនទៀង** | ជាប្រធាន | មានឋានៈស្មើ ទេសរដ្ឋមន្ត្រី |
| ២- ឯកឧត្តម **ចាន់ មិន** | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៣- ឯកឧត្តម **អ៊ិត រ៉ាឌី** | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៤- ឯកឧត្តម **ម៉ក់ សម្បត្តិ** | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម **អ៊ិច ភាន** | ជាអនុប្រធាន | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៦- លោកជំទាវ **ពុំ ចាន់ធីនី** | ជាសមាជិកា | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៧- ឯកឧត្តម **ហេង្ស ឡារ៉ាម៉ានី** | ជាសមាជិក | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៨- ឯកឧត្តម **តិច ចន្ទ័តារា** | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៩- ឯកឧត្តម **នូ ស្លាបត្យា** | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១០- ឯកឧត្តម **ប៉ែន ស៊ីន** | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១១- ឯកឧត្តម **ភត្តា អ៊ិន** | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

| | | |
|---|---|---|
| ១២- ឯកឧត្តម ប៊ុ គុយសេង | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៣- ឯកឧត្តម ឈួន ចាន់ថន | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៤- ឯកឧត្តម ជេត ជាលី | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៥- ឯកឧត្តម អ៊ិច សេង | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៦- ឯកឧត្តម ម៉ែន សុផល | ជាសមាជិក | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ១៧- លោកជំទាវ សុខ សុម៉ាលី | ជាសមាជិកា | មានឋានៈស្មើ អគ្គនាយក |
| ១៨- ឯកឧត្តម ពេញ ធារម្យ | ជាសមាជិក | មានឋានៈស្មើ អគ្គនាយក |
| ១៩- ឯកឧត្តម សៅ លី | ជាសមាជិក | មានឋានៈស្មើ អគ្គនាយក |

**មាត្រា ២:** ត្រូវបានកែសម្រួលមាត្រា ៥ របស់ព្រះរាជក្រឹត្យ លេខ នស / រកត / ០១០០ / ០០៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដូចតទៅ៖

**មាត្រា ៥ ថ្មី:** គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាមាន ២ អគ្គនាយកដ្ឋាន៖

១- អគ្គនាយកដ្ឋានស៊ើបអង្កេត និងអប់រំសិទ្ធិមនុស្ស: ទទួលការងារបច្ចេកទេសពាក់ព័ន្ធលើការស្រាវជ្រាវប្រមូលពត៌មាន ឯកសារ ធ្វើរបាយការណ៍ពីបទរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់ កោសល្យវិច្ច័យជំនាញនានា និងទទួលតាមផ្នែកនីមួយៗនៃអនុសញ្ញាអន្តរជាតិ បណ្តុះបណ្តាលអប់រំផ្សព្វផ្សាយសិទ្ធិមនុស្ស រៀបចំវេទិកា សាធារណៈមតិ និងបើកលទ្ធភាពឱ្យមានការសួរដេញដោលដោយសេរី ។

២- អគ្គនាយកដ្ឋានរដ្ឋបាល និងពាក្យបណ្តឹង: ទទួលការងាររដ្ឋបាល ហិរញ្ញវត្ថុ គ្រប់គ្រង និងសេវានានាបំរើឱ្យគណៈកម្មាធិការ ទំនាក់ទំនងសាធារណៈ ពាក្យបណ្តឹងតវ៉ា រៀបចំបណ្តាញ និងបណ្តុះបណ្តាលមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សពិសេសលើកទឹកចិត្តដោះស្រាយទំនាស់តាមរបៀបសម្រុះសម្រួល ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចស្នើតែងតាំងទីប្រឹក្សា និងអ្នកជំនាញការខ្មែរ និងបរទេសអមគណៈកម្មាធិការដើម្បីជួយសិក្សា និងផ្តល់យោបល់ពីការងារជំនាញនីមួយៗ ។ ទីប្រឹក្សាអ្នកជំនាញការខ្មែរអាចមានឋានៈពីប្រធាននាយកដ្ឋានឡើងទៅ ។

**មាត្រា ៣:** រាល់បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ៕

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៩*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់**

**ប្រមុខរដ្ឋស្តីទី**

**ប្រធានព្រឹទ្ធសភា**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

*៣៧.០៩០២.១៦៦*

លេខ : ១៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០០៩

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ស៊ុន ជិនគេន